ក

មាតិកា

I-ខុទ្ទកាណ័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

១៥-០២-២០០៨-ព្រះរាជក្រម នស/រកម/០២០៨/០០៥ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២១២២

២-ព្រះរាជក្រឹត្យ

០៥-៣-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០៣០៨/២១៧ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជាតាមឋានានុក្រមដល់ សមាជិក សមាជិកា រដ្ឋសភា នីតិកាលទី ៣ លើកទី ២ ចំនួន ១២៣ រូប និងអគ្គលេខាធិការ អគ្គលេខាធិការរង នៃអគ្គលេខា ធិការដ្ឋានរដ្ឋសភា ចំនួន ៤ រូប ២១៤៦

០៧-៣-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០៣០៨/២២០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សបុច្ឆិ ជូនចំពោះអស់លោក ចំនួន ០៣ រូប ២១៥៦

០៧-៣-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០៣០៨/២២១ ស្តីពីការប្រោសព្រះរាជទាន ចំពោះនាយទាហាន នៃកងយោធពលខេមរភូមិន្ទ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្ស បុច្ឆិ ចំនួន ០៩ រូប ២១៥៧

០៧-៣-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០៣០៨/២២៧ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៤ រូប ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ២១៥៨

០៧-៣-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០៣០៨/២២៨ ស្តីពីការតែងតាំងលោកជំទាវ **មាន ស្រីណុ** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ២១៥៩

๐๗-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๒๕ ស្តីពីការតម្លើងឋានន្តរស័ក្តិឯកឧត្តម **ឆួច សីឥហាយ** ពីឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ ๔ ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ๕ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ๒๑๖๐

๐๗-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๓๐ ស្តីពីការតែងតាំងឯកឧត្តម **ឃឹម យ៉ាន់** ជាទីប្រឹក្សាក្រសួងសុខាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ๒๑๖๑

๐๗-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๓๑ ស្តីពីការតែងតាំងឯកឧត្តម **ឈន ព្រឆឹង** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ๒๑๖๒

๐๗-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๓๒ ស្តីពីការតែងតាំងឯកឧត្តមបណ្ឌិត **ចំន្ទ សំណាង** ជាអនុប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ๒๑๖๓

๐๗-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๓๕ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា និង គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ឧកញ៉ា, ឯកឧត្តម,លោកជំទាវ និងអស់លោក ចំនួន ๐๖ រូប ๒๑๖๔

๐๘-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๓๖ ស្តីពីការប្រោសព្រះរាជទានប្រគេន ព្រះឃោសបាល **សៅ មុនី** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ๒๑๖๕

๐๘-๓-๒๐๐๘ -ព្រះរាជក្រឹត្យ នស/រកត/๐๓๐๘/๒๓๗ ស្តីពីការតែងតាំងឯកឧត្តមចំនួន ๐๒ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ๒๑๖๖

๐๘-๓-๒๐๐๘ -ព្រះរាជក្រឹត្យនស/រកត/๐๓๐๘/๒๓๘ស្តីពីការតែងតាំងឯកឧត្តម **ឈឿង យ៉ាណារ៉ា** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ๒๑๖๗

គ

0៨-៣-២00៨ -ព្រះរាជក្រឹត្យ នស/រកត/0៣0៨/២៣៩ ស្តីពីការតម្លើងឋានៈស្មើ ទេសរដ្ឋមន្ត្រី ជូន ឯកឧត្តម **សុខ ចិន្តា** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះ រាជាណាចក្រកម្ពុជា ២១៦៨

0៨-៣-២00៨ -ព្រះរាជក្រឹត្យនស/រកត/0៣0៨/២៤0ស្តីពីការតម្លើងឋានៈស្មើ ទេសរដ្ឋមន្ត្រី ជូន ឯកឧត្តម **ខុល គឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ២១៦៩

0៨-៣-២00៨ -ព្រះរាជក្រឹត្យ នស/រកត/0៣0៨/២៤១ ស្តីពីការផ្ទេរក្របខ័ណ្ឌលោក **ង៉ែ ប៊ុនឈ្វីន** និងលោកជំទាវ **ពៅ សុខន** បច្ចុប្បន្ន អនុមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងទេសចរណ៍ ទៅជាអនុមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៅក្រសួងមហាផ្ទៃ ២១៧0

0៨-៣-២00៨ -ព្រះរាជក្រឹត្យ នស/រកត/0៣0៨/២៤២ ស្តីពីការតែងតាំងឯកឧត្តម **ជាន់ ហួរ** ជាអគ្គលេខាធិការ នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយក ២១៧១

0៨-៣-២00៨ -ព្រះរាជក្រឹត្យ នស/រកត/0៣0៨/២៤៣ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ ជូនចំពោះអស់លោក ចំនួន ១១ រូប ២១៧២

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៧-៣-២00៨ -អនុក្រឹត្យលេខ ២៤អនក្រ.បកស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ(ផ្នែក A) ២១៧៣

១៧-៣-២00៨ -អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ផ្នែក B,C,D,E និង F) ២១៧៦

0៦-៣-២00៨ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារភ័ណ្ឌ ២១៧៩

0៧-៣-២00៨ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៨0

០៧-៣-២០០៨	-អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា	២១៨១
០៧-៣-២០០៨	-អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ	២១៨៣
១១-៣-២០០៨	-អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២១៨៤
១១-៣-២០០៨	-អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២១៨៥
១១-៣-២០០៨	-អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២១៨៦
១១-៣-២០០៨	-អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២១៨៧
១១-៣-២០០៨	-អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២១៨៩
១១-៣-២០០៨	-អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២១៩១
១១-៣-២០០៨	-អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២១៩២
១១-៣-២០០៨	-អនុក្រឹត្យលេខ ២៣២ អនក្រ.តត ស្តីពីការបំពាក់ឋានន្តរស័ក្តិនាយនគរបាលជាតិ	២១៩៤
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២១៩៥
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២១៩៩
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២០១
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២២០៧
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្តីពីការបំពាក់មេដាយស្ថាបនាជាតិ	២២១២
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត	២២១៤
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ	២២១៥
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការ	២២១៦
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២២១៧
១២-៣-២០០៨	-អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២២១៨

១២-៣-២០០៨ -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២២០
១២-៣-២០០៨ -អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២២២១
១២-៣-២០០៨ -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២២២៤
១២-៣-២០០៨ -អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២២២៧
១៣-៣-២០០៨ -អនុក្រឹត្យលេខ ២៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២២៩
១៣-៣-២០០៨ -អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២៣០
១៣-៣-២០០៨ -អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២៣១
១៣-៣-២០០៨ -អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២២៣២

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៣-៤-២០០៧ -លិខិតបញ្ជាក់លេខ ១៥៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថ្លែស ថេក**	២២៣៣
២៣-៤-២០០៧ -លិខិតបញ្ជាក់លេខ ១៥៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តឺ.តឺ.អាយ ត្រាវែល** & **ជួរ**	២២៣៥
២៣-៤-២០០៧ -លិខិតបញ្ជាក់លេខ ១៥៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រក្សាសម្បត្តិ**	២២៣៧
២៣-៤-២០០៧ -លិខិតបញ្ជាក់លេខ ១៥៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ម៉ាឡេស៊ី ស្ត្រេធីឌីក ឌេវី ខប**	២២៣៩
២៣-៤-២០០៧ -លិខិតបញ្ជាក់លេខ ១៥៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រឺ កូ**	២២៤១
២៣-៤-២០០៧ -លិខិតបញ្ជាក់លេខ ១៥៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌូ ម៉ា ខប**	២២៤៣

ព្រះរាជក្រម

នស/រកម/០២០៨/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិន្ទាតិសាសនា រក្ខគខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាថនា សមូរហោភាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុភមង្គលា សីរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីដូចតទៅនេះ :

ច្បាប់

ស្តីពី

ការចុះបញ្ជីអំពីដំណឹងមន្ទិលសង្ស័យ
អំពីជម្លោះដីធ្លីក្នុងដែន

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.- គោលបំណងនៃច្បាប់នេះ

ច្បាប់នេះ មានគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើនឱ្យសុខភាព និងសុខុមាលភាព របស់ប្រជាពលរដ្ឋ និង រក្សាការពារ លើកកម្ពស់ទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឱ្យ បានសមស្របជាងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ឬ ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ទាក់ទងនឹងការជួញដូរមនុស្សដែលព្រះរាជាណាចក្រ កម្ពុជាបានឱ្យសច្ចាប័ន ឬ ចុះហត្ថលេខា ។

មាត្រា ២.- ការអនុវត្តច្បាប់នេះនៅក្នុងដែនដី

ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើស ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងដែនដីនៃព្រះ-រាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងច្បាប់នេះ រួមបញ្ចូលទាំងនាវា ឬ អាកាស-យានណាមួយដែលមានសិទ្ធិប្រើប្រាស់ទង់ជាតិកម្ពុជា ។

បទល្មើសមួយត្រូវចាត់ទុកថា បានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើរួមផ្សំណាមួយនៃបទល្មើសនោះកើតឡើងនៅក្នុងដែនដីនៃព្រះរាជាណា-ចក្រកម្ពុជា ។

មាត្រា ៣.- ការអនុវត្តច្បាប់នេះនៅក្រៅដែនដី

ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលត្រូវបានប្រព្រឹត្ត ឡើងក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីវាំង

ច្បាប់នេះអនុវត្តទៅលើបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយជនបរទេស ហើយជនរងគ្រោះគឺជាពលរដ្ឋខ្មែរនៅពេលដែលបទល្មើសកើតឡើង ។

មាត្រា ៤.- ការឧទ្ធរណ៍ខុសត្រូវផ្នែកព្រហ្មទណ្ឌ

រាល់ការប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោស និងត្រូវទទួលខុសត្រូវ ដូចករណីដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

អ្នកសមគំនិត និង អ្នកផ្តើមគំនិត ក្នុងបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោស និងត្រូវទទួលខុសត្រូវដូចចារីដែលប្រព្រឹត្តបទល្មើស ។

អ្នកសមគំនិត និងអ្នកផ្តើមគំនិតរួមមាន អ្នករៀបចំ ឬ ចង្អុលបង្ហាញជាអាទិ៍ឱ្យជនដទៃប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ ។

នៅពេលដែលអ្នកតំណាង ភ្នាក់ងារ ឬ និយោជិត នៃនីតិបុគ្គល ឬ ភារយ៉ូទាយីណាមួយប្រព្រឹត្តបទល្មើសណាមួយ ដែលមានចែងនៅក្នុងច្បាប់នេះ ក្នុងក្របខ័ណ្ឌនៃមុខជំនួញ ឬ ជលប្រយោជន៍នៃនីតិបុគ្គល ឬ ភារយ៉ូទាយីនោះ នីតិបុគ្គល ឬ ភារយ៉ូទាយីនោះ ត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់ និង ទោសបន្ថែម ដោយយោងទៅតាមការផ្តន្ទាទោសដែលមានចែងនៅក្នុងមាត្រាដែលពាក់ព័ន្ធ ។

មាត្រា ៥.- ការប្រកាសមូលដ្ឋានទោស

នៅក្នុងគ្រប់ករណី ដែលបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារផង និង ពិន័យជាប្រាក់ផង តុលាការអាចប្រកាស :

១-ទោសជាប់ពន្ធនាគារ និងទោសពិន័យត្រួតគ្នា ។

២-ទោសដាក់ពន្ធនាគារតែមួយប៉ុណ្ណោះ ។

៣-ឬក៏ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

មាត្រា ៦.- បទល្មើសត្រួតគ្នា

កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានបទល្មើសច្រើន ទោសនីមួយៗ អាចត្រូវប្រកាសឡើង ។ ប៉ុន្តែកាលបើទោសត្រូវទទួលច្រើន និងមានប្រភេទដូចគ្នា ទោសតែមួយនៃប្រភេទនេះ អាចត្រូវបានប្រកាសជាអតិ-
ក្នុងកម្រិតដែលខ្ពស់ជាងគេ ។

MINISTRE DU PALAIS ROYAL

មាត្រា ៧.- និយមន័យនៃអនីតិជន

អនីតិជន នៅក្នុងច្បាប់នេះមានន័យថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។

ជនណាដែលរក្សាទុកអនីតិជនឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួន នឹងត្រូវចាត់ទុកថា បានដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះបង្ហាញឱ្យឃើញថា ខ្លួនមានការជឿជាក់ដោយសមហេតុផលថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬច្រើនជាង ១៨ ឆ្នាំ ។

ជំពូកទី ២
អំពើល្មក-ជូរមនុស្ស

មាត្រា ៨.- និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់

ការនាំយកចេញដោយមិនស្របច្បាប់ នៅក្នុងច្បាប់នេះមានន័យថា :

១-ការធ្វើឱ្យមនុស្សម្នាក់ ផ្ទាស់ទីពីទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងផ្សេងដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជន តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង ចោកបញ្ឆោត បំពានដោយអំណាច ឬ ល្មងលោម ។

២-ការនាំយកអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលរបស់គេ ។

មាត្រា ៩.- ការនាំយកអនីតិជន ជាអាណិ ចេញដោយមិនស្របច្បាប់

ជនណានាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិ-តូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ចេញដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ ការផ្តន្ទាទោសត្រូវលើកលែង ឬ ទទួលស្គាល់ ក្នុងករណីលក្ខខណ្ឌទាំងអស់ ត្រូវបានបំពេញដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១-បើជនស្ថិតនៅក្រោមការគ្រប់គ្រង ដែលគេនាំយកទៅនោះ មានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ និងយល់ព្រមដោយស្ម័គ្រចិត្ត ចំពោះអំពើល្មើស ។

២-ការពុំមានប្រើវិធានការណាមួយ ដែលមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើប្រាស់ ។

៣-ជនល្មើសមិនមានគោលបំណង ប្រព្រឹត្តបទល្មើសណាមួយ ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ អាចធ្វើការចោទប្រកាន់បាន លុះត្រាតែមានពាក្យបណ្តឹងពីឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលស្របច្បាប់ ប្រសិនបើមធ្យោបាយណាមួយដូចមានចែងនៅក្នុងកថាខណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើប្រាស់ ។

មាត្រា ១០.- ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ

ជនណាដែលនាំយកជនជនៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្មានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចាន៍ផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់ ១៥(ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែល :

-ជនរងគ្រោះជាអនីតិជន ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

ពាក្យថា ទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត នៅក្នុងមាត្រានេះ និងមាត្រា ១២ មាត្រា ១៥ មាត្រា ១៧ និងមាត្រា ១៩ នៃច្បាប់នេះ រួមមាន ការកេងប្រវ័ញ្ចន៍លើពេស្យាកម្មជនជនៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុលសេវាភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការជកហូតសរីរាង្គ ។

ការយល់ព្រមរបស់ជនរងគ្រោះចំពោះគោលដៅដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មិនទាក់ទងនឹងមធ្យោបាយណាមួយដែលមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ដែលត្រូវបានប្រើនោះទេ ។ ករណីនេះត្រូវយកទៅអនុវត្តផងដែរ ចំពោះបទល្មើស ដែលមានចែងក្នុងមាត្រា ១៥ មាត្រា ១៧ និងមាត្រា ១៩ នៃច្បាប់នេះ ។

មាត្រា ១១.- ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន

ជនណាដែលបាននាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី ១ ខាងលើ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ)ឆ្នាំ ក្នុងករណីដែល :

-ជនរងគ្រោះជាអនីតិជន ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

មាត្រា ១២.- ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍

ការជ្រើសរើសដោយមិនស្របច្បាប់នៅក្នុងច្បាប់នេះ មានន័យថា ការបញ្ចុះបញ្ចូល ការជួល ឬ ការឱ្យជនណាមួយបម្រើការក្រោមទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត តាមមធ្យោបាយចោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគម្រាមកំហែង ឬ មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត ។

ជនណាដែលជ្រើសរើសជនដទៃដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែល :

-ជនរងគ្រោះជាអនីតិជន ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

មាត្រា ១៣.- និយមន័យនៃអំពើលក់-ជួរមនុស្ស

អំពើលក់-ជួរមនុស្សមានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង ។

អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ជួរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងអំពើលក់-ជួរមនុស្សដោយផ្ទាល់ ។

មាត្រា ១៤.- អំពើលក់-ជួរមនុស្ស

ជនណាដែលលក់-ជួរជនដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

មាត្រា ១៥.- អំពើលក់-ជួរមនុស្សដោយមានគោលដៅ

ជនណាដែលលក់-ជួរជនដទៃ ដោយមានគោលដៅស្វែងរកប្រយោជន៍ ឈ្មានពានខាងផ្លូវភេទ ជលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ដល់ ២០(ម្ភៃ)ឆ្នាំ ក្នុងករណីដែល :

-ជនរងគ្រោះជាអនីតិជន ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

មាត្រា ១៦.- អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន

ជនណាដែលលក់-ដូរជនដទៃ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់ ១៥ (ដប់ប្រាំ)ឆ្នាំ ។

ជនណាដែលលក់-ដូរជនដទៃ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះ ទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី ១ ខាងលើ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ២០ (ម្ភៃ)ឆ្នាំ ក្នុងករណីដែល :

-ជនរងគ្រោះជាអនីតិជន ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

មាត្រា ១៧.- ការដឹកជញ្ជូនដោយមានគោលដៅ

ជនណាដែលដឹកជញ្ជូនជនដទៃ ដែលត្រូវបាននាំយកចេញដោយមិនស្របច្បាប់ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយដឹងថាជននោះត្រូវបាននាំយកចេញដោយមិនស្របច្បាប់ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ឈ្មានពានខាងផ្លូវភេទ ជលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ស៊ុកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ២០ (ម្ភៃ)ឆ្នាំ ក្នុងករណីដែល :

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ១៨.- អំពើនាំឆ្លងដែន

ជនណាដែលនាំយកជនដទៃ ដោយដឹងថាជននោះ ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ជនណាដែលនាំយកជនដទៃ ដោយដឹងថាជននោះ ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី ១ ខាងលើ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ក្នុងករណីដែល :

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

មាត្រា ១៩.- ការទទួលយកមនុស្សដោយមានគោលដៅ

ជនណាដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួនជនណាមួយ ដែលបានមកពីអំពើនាំយកចេញដោយមិនស្របច្បាប់ ឬ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនក្នុងគោលដៅ ដើម្បីស្វែងរកប្រយោជន៍ ឈ្មានពានខាងផ្លូវភេទ ផលិតរូបភាព អាសអាភាស អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំភ្ងន ឬ ទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ក្នុងករណីដែល :

-ជនរងគ្រោះជាអនីតិជន ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ២០.- ការឧទ្ធរណ៍យកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស

ជនណាដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនរងគ្រោះក្នុងអំពើនាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ផ្សរ ឬ ដឹកជញ្ជូន ក្នុងគោលដៅដើម្បីជួយដល់ជនល្មើសដែលបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ផ្សរ ឬ ដឹកជញ្ជូនជនរងគ្រោះនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន ។

ជំពូកទី ៣
ការបង្ខាំង

មាត្រា ២១.- ការចាប់ពន្ធនៈ ការឃុំឃាំង ឬ ការបង្ខាំង

បុគ្គលដែលចាប់ឃុំឃាំង ឬ បង្ខាំងជនដទៃ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ត្រូវផ្តន្ទាទោស :

១-ជាប់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួន មានរយៈពេលតិចជាងមួយខែ ។

២-ជាប់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួន មានរយៈពេលស្មើ ឬ លើសពីមួយខែ ។

មាត្រា ២២.- ស្ថានទម្ងន់ទោស

បុគ្គលដែលចាប់ឃុំឃាំង ឬ បង្ខាំងជនដទៃ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីដូចខាងក្រោម :

១-ដោយមានទារុណកម្ម ឬ អំពើឃោរឃៅ

២-បណ្តាលឱ្យមានមនុស្សស្លាប់ ឬ

៣-ប្រព្រឹត្តក្នុងគោលដៅជំរិតយកប្រាក់ ។

ជំពូកទី ៤

អំពើពេស្យាចារ និង អំពើពេស្យាចារកុមារ

មាត្រា ២៣.- និយមន័យនៃអំពើពេស្យាចារ និង អំពើពេស្យាចារកុមារ

"អំពើពេស្យាចារ" នៅក្នុងច្បាប់នេះមានន័យថា ការរួមភេទជាមួយជនណាម្នាក់ដែលមិនកំណត់ ឬ អំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ ដោយផ្តោះប្តូរនឹងវត្ថុមានតម្លៃអ្វីមួយ ។

"អំពើពេស្យាចារកុមារ" នៅក្នុងច្បាប់នេះមានន័យថា ជាអំពើរួមភេទ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទ រវាងអនីតិជនជាមួយជនដទៃ ដើម្បីផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ។

មាត្រា ២៤.- អំពើអូសទាញ

ជនណាអូសទាញដោយចេតនានូវជនដទៃក្នុងទីសាធារណៈក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ដល់ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ៣.០០០ (បីពាន់) រៀល ដល់ ១០.០០០ (មួយម៉ឺន) រៀល ។

អនីតិជនត្រូវលើកលែងពីការផ្តន្ទាទោសចំពោះបទល្មើស ដូចមានចែងនៅក្នុងមាត្រានេះ ។

មាត្រា ២៥.- និយមន័យនៃសញ្ជារកម្ម

អំពើសញ្ជារកម្ម នៅក្នុងច្បាប់នេះ មានន័យថា :

១-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

២-ជួយ ឬ ការពារអំពើពេស្យាចាររបស់ជនដទៃ

៣-ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ

៤-ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។

ROYAUME DU CAMBODGE * TAKEO * LE MINISTRE DU PALAIS ROYAL

អំពើដូចខាងក្រោមនេះ ត្រូវចាត់ទុកថា ដូចគ្នាទៅនឹងសញ្ជាវកម្ម :

១-អំពើធ្វើជាអន្តរការីរវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬឱ្យលាភការដល់ពេស្យាចារជនដទៃ ។

២-អំពើរបស់ជនណាដែលបានជួយសម្រួល ឬបិទបាំងនូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ជាវកម្ម ។

៣-អំពើរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬដោយអង្គការឯកជនដែលមានន័តិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬកំពុងមានគ្រោះ ដោយការធ្វើពេស្យាចារ ។

មាត្រា ២៦.- សញ្ជាវកម្ម

ជនណាដែលប្រព្រឹត្តសញ្ជាវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

មាត្រា ២៧.- ស្ថានទម្ងន់ទោសនៃសញ្ជាវកម្ម

ជនណាប្រព្រឹត្តសញ្ជាវកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចខាងក្រោមនេះ :

១-កាលបើសញ្ជាវិក សញ្ជាវិកា ឬជនជាមេពេស្យាជាបុព្វញ្ញាតិ ឬបច្ឆាញ្ញាតិ មានខាន់ស្លា អត់ខាន់ស្លា ឬសាច់បង្កើត ឬចិញ្ចឹមរបស់បុគ្គលដែលធ្វើពេស្យាចារ ។

២-កាលបើសញ្ជាវិក សញ្ជាវិកា ឬជនជាមេពេស្យា រំលោភអំណាច ដែលមុខងាររបស់ខ្លួនផ្តល់ឱ្យទៅលើបុគ្គលដែលធ្វើពេស្យាចារ ។

៣-កាលបើសញ្ជាវិក សញ្ជាវិកា ឬជនជាមេពេស្យាប្រើហឹង្សា ឬការបង្ខិតបង្ខំ ចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

៤-កាលបើសញ្ជាវកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

៥-កាលបើសញ្ជាវកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ ។

មាត្រា ២៨.- សញ្ជាវកម្មទាក់ទងនឹងពេស្យាចារកុមារ

សញ្ជាវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ ក្នុងករណីបុគ្គលដែលធ្វើពេស្យាចារនោះជាអនីតិជន ។

ពាក្យថា "ពេស្យាចារ" នៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃជំពូកនេះ ត្រូវជំនួសដោយពាក្យ "ពេស្យាចារកុមារ" នៅពេលដែលបទល្មើសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវអនុវត្ត ។

មាត្រា ២៩.- សញ្ជារកម្មដោយមានការធ្វើទារុណកម្ម

សញ្ជារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០(ម្ភៃ) ឆ្នាំ កាលបើសញ្ជារិក សញ្ជារិកា ឬ មេពេស្យាបានប្រើទារុណកម្ម ឬ អំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

មាត្រា ៣០.- ការដឹកនាំពេស្យាចារ

ជនណាដឹកនាំ ធ្វើអាជីវកម្ម ធ្វើប្រតិបត្តិការ ឬ ចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារដោយផ្ទាល់ ឬ តាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

មាត្រា ៣១.- ការដឹកនាំគ្រឹះស្ថានពេស្យាចារ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើបានយល់ព្រម ឬ បានអនុគ្រោះ :

១-ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ឬ

២-ឱ្យបុគ្គលណាម្នាក់រកភៀវ ដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាននេះ ។

មាត្រា ៣២.- ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ

ជនណាលក់ ឬ ជាក់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែង ដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងថាបុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើសកម្ម-ភាពពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

មាត្រា ៣៣.- បទល្មើសទាក់ទងនឹងពេស្យាចារកុមារ

ជនណាប្រព្រឹត្តបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣០ មាត្រា ៣១ និង មាត្រា ៣២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ បើបទល្មើសដែលបានប្រព្រឹត្តនោះទាក់ទងនឹងពេស្យាចារកុមារ ។

ពាក្យថា "ពេស្យាចារ" នៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃជំពូកនេះ ត្រូវជំនួសដោយ ពាក្យ "ពេស្យាចារកុមារ" នៅពេលដែលបទល្មើសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះត្រូវអនុវត្ត ។

មាត្រា ៣៤.- ការធ្វើពេស្យាចារកុមារ

ជនណារួមភេទ ឬ ធ្វើអំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទជាមួយអនីតិជន ដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅដោយផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ ទៅឱ្យអនីតិជននោះ ឬ ទៅឱ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬ ជនដទៃទៀតដែល គ្រប់គ្រង ឬ ត្រួតពិនិត្យលើអនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

ជនណាដែលប្រព្រឹត្តបទល្មើសខាងលើ ជាមួយអនីតិជនដែលមានអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់ ១៥ (ដប់ប្រាំ)ឆ្នាំ ។

មាត្រា ៣៥.- អំពើអូសទាញពេស្យាចារកុមារ

ជនណាអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារ ឬ ផ្សាយពាណិជ្ជកម្មនូវអំពើ ពេស្យាចារកុមារក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

ជនណាប្រព្រឹត្តបទល្មើសខាងលើធ្វើជាមុខរបរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ដល់ ១០ (ដប់)ឆ្នាំ ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL *

មាត្រា ៣៦.- ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌនាក់ទងទៅនឹងអំពើពេស្យាចារកុមារ

ជនណាឱ្យជនជនជាខ្ចីប្រាក់ ឬ វត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជន ប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

ជនណាឱ្យអនីតិជនខ្ចីប្រាក់ ឬ វត្ថុមានតម្លៃអ្វីមួយ ដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជននោះ ប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី ១ នៃមាត្រានេះ ។

មាត្រា ៣៧.- កិច្ចសន្យានៃអំពើពេស្យាចារកុមារ

ជនណាធ្វើកិច្ចសន្យាជាមួយជនជនជាដែលក្នុងកិច្ចសន្យានោះតម្រូវឱ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

ជនណាធ្វើកិច្ចសន្យាជាមួយអនីតិជនដែលក្នុងកិច្ចសន្យានោះតម្រូវឱ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី ១ នៃមាត្រានេះ ។

ជំពូកទី ៥

រូបភាព និង សម្ភារៈអាសអាភាស

មាត្រា ៣៨.- និយមន័យនៃរូបភាព និង សម្ភារៈអាសអាភាស

រូបភាព និង សម្ភារៈអាសអាភាស នៅក្នុងច្បាប់នេះមានន័យថា ជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលពិពណ៌នាអំពីភេរវកម្ម ឬ ភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ ។

មាត្រា ៣៩.- រូបភាព និង សម្ភារៈអាសអាភាស

ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញនៅទីសាធារណៈនូវរូបភាព និង សម្ភារៈអាសអាភាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ថ្ងៃ ដល់ ១ (មួយ) ខែ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ២០០.០០០ (ពីរសែន)រៀល ។

ROYAUME DU CAMBODGE LE MINISTRE DE PALAIS ROYAL

ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវរូបភាព និងសម្ភារៈអាសអាភាស ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដូចគ្នា នឹងកថាខណ្ឌទី ១ ខាងលើ ។

ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ដល់ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ២០០.០០០ (ពីរសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ។

មាត្រា ៤០.- និយមន័យនៃរូបភាព និង សម្ភារៈអាសអាភាសនៃកុមារ

រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ នៅក្នុងច្បាប់នេះមានន័យថា សម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈ អេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជនដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ ។

មាត្រា ៤១.- រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ

ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើត្រូវផ្តន្ទាទោសដូចគ្នា ។

ជនណាផលិតរូបភាព និង សម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ។

ជនណាផលិតរូបភាព និង សម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
MINISTRE du PALAIS ROYAL

ជំពូកទី ៦

អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ

មាត្រា ៤២.- អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ

ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ ត្រូវផ្តន្ទា-ទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

មាត្រា ៤៣.- អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ

អំពើអាសនៅក្នុងច្បាប់នេះ មានន័យថា ជាអំពើនៃការប៉ះពាល់ ឬ ការបង្ហាញភេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់ភេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជនក្នុងចេតនាធ្វើឱ្យរំជួល ឬរីករាយផ្ទាល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

ជនណាដែលប្រព្រឹត្តអំពើអាសទៅលើជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤២ ឬ មាត្រានេះ បើមិនរាងចាលទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារទ្វេដង ។

មាត្រា ៤៤.- ការលើកលែងពីការផ្តន្ទាទោស

ជនណាដែលមានអាយុក្រោម ១៥ ឆ្នាំ នឹងត្រូវលើកលែងពីការផ្តន្ទាទោស ចំពោះបទល្មើសដូចមានចែងនៅក្នុងមាត្រា ៤២ និងមាត្រា ៤៣ នៃច្បាប់នេះ ។

ជំពូកទី ៧

សំណងរដ្ឋប្បវេណី

មាត្រា ៤៥.- កិច្ចសន្យាសម្រាប់អំពើលក់-ជូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

កិច្ចសន្យាមួយនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យានោះត្រូវបានធ្វើឡើងដើម្បីគេចវេរបំពេញនូវអំពើលក់-ជូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

កិច្ចសន្យាឱ្យខ្ចីនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយភ្ជាប់ទៅនឹងអំពើលក់-ជួរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ ។

"អំពើលក់-ជួរមនុស្ស" ឬ "អំពើធ្វើអាជីវកម្មផ្លូវភេទ" នៅក្នុងមាត្រានេះ និងមាត្រាបន្តបន្ទាប់មានន័យថា ជាអំពើខុសច្បាប់ដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់នេះ ។

មាត្រា ៤៦.- សំណងបដិទានលើការទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល

ជនណាទទួលយកនូវផលប្រយោជន៍ ដោយគ្មានហេតុផលស្របច្បាប់ ដោយដឹងថាផលប្រយោជន៍នោះ បានមកពីអំពើលក់-ជួរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទនឹងត្រូវទទួលខុសត្រូវលើសំណងបដិទានចំពោះអំពើទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផលព្រមទាំងការប្រាក់ដែលកើតឡើង ។

ជនដែលត្រូវគេកេងយកប្រយោជន៍ អាចប្តឹងទាមទារសំណងលើការខូចខាតជាបន្ថែមលើសំណងបដិទាន ចំពោះអំពើទទួលបានផលប្រយោជន៍ដោយមិនសមហេតុផល ។

ជនណាបានបង្កើតកិច្ចសន្យាឱ្យខ្ចី ឬ ការផ្តល់ផ្សេងទៀតទៅជនដទៃក្នុងគោលដៅធ្វើការលក់-ជួរមនុស្ស ឬ ធ្វើអាជីវកម្មផ្លូវភេទ មិនអាចប្តឹងទាមទារសំណងបដិទាន ចំពោះការផ្តល់នោះបានទេ ។

មាត្រា ៤៧.- សិទ្ធិជាអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិដែលត្រូវចាត់គេរឹបអូស

ជនរងគ្រោះ ត្រូវទទួលបានដោយអាទិភាពនូវទ្រព្យដែលត្រូវបានរឹបអូសដោយរដ្ឋ សម្រាប់ជាសំណងលើការខូចខាត និង សំណងបដិទានដល់ជនរងគ្រោះនោះ ។

ជំពូកទី ៨
បទប្បញ្ញត្តិបន្ថែម

មាត្រា ៤៨.- ទោសបន្ថែម

ចំពោះបទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ អាចត្រូវទទួលទោសបន្ថែមដូច

ROYAUME du CAMBODGE • ... TRE du PALAIS ROYAL •

១-រឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុទាំងឡាយដែលត្រូវបានប្រើប្រាស់ ឬ នឹងត្រូវប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស

២-រឹបអូសសម្ភារៈទាំងឡាយ ដែលជាកម្មវត្ថុនៃបទល្មើស

៣-រឹបអូសប្រាក់ចំណូល ឬ ទ្រព្យដែលរកបាន ឬ ជាផលនៃបទល្មើស

៤-បិទការផលិត ដែលបម្រើដល់ការប្រព្រឹត្តបទល្មើស

៥-ការដាក់កំហិតលើសិទ្ធិពលរដ្ឋ និង

៦-ការហាមឃាត់ការស្នាក់នៅ ។

មាត្រា ៤៩.- ការណាក់ចាំងនូវអត្តសញ្ញាណនៃជនរងគ្រោះ

សារព័ត៌មាន និងគ្រប់មធ្យោបាយផ្សព្វផ្សាយដទៃទៀត ត្រូវហាមឃាត់មិនឱ្យធ្វើការចោះពុម្ពផ្សាយ ឬ ផ្សព្វផ្សាយនូវព័ត៌មាន ដែលអាចធ្វើឱ្យសាធារណជនដឹងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះក្នុងបទល្មើសទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ ។

ជំពូកទី ៩

អវសានប្បញ្ញត្តិ

មាត្រា ៥០.- និរាករណ៍នៃច្បាប់ដែលផ្ទុយ

ច្បាប់ស្តីពី "ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស" ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៦/០១ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវមានអាទិភាព ប្រសិនបើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៥១.- ការជំនួសដោយក្រមព្រហ្មទណ្ឌ

មាត្រា ២ មាត្រា ៣ មាត្រា ៤ និង មាត្រា ៦ នៃច្បាប់នេះ ត្រូវជំនួសដោយបទប្បញ្ញត្តិ ឬ ទណ្ឌកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៅពេលដែលក្រមនោះចូលជា

មាត្រា ៥២.- ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០០៨

ព្រះហស្តលេខា និងព្រះរាជលញ្ជីការ

នរោត្តម សីហមុនី

៣៧.០៨០២.១៣២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្សវឌ្ឍានា

លេខ : ១៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០៨
អគ្គលេខាធិការរដ្ឋាភិបាល

ជិន ភេទ

មាតិកា

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

មាត្រា ១ គោលបំណងនៃច្បាប់នេះ

មាត្រា ២ ការអនុវត្តច្បាប់នេះនៅក្នុងដែនដី

មាត្រា ៣ ការអនុវត្តច្បាប់នេះនៅក្រៅដែនដី

មាត្រា ៤ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

មាត្រា ៥ ការប្រកាសមួលទោស

មាត្រា ៦ បទល្មើសត្រួតគ្នា

មាត្រា ៧ និយមន័យនៃអនីតិជន

ជំពូកទី ២ អំពើលក់ដូរមនុស្ស

មាត្រា ៨ និយមន័យនៃការយកចេញដោយមិនស្របច្បាប់

មាត្រា ៩ ការនាំយកអនីតិជន ជាអាទិ៍ ចេញដោយមិនស្របច្បាប់

មាត្រា ១០ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ

មាត្រា ១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន

មាត្រា ១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច៍

មាត្រា ១៣ និយមន័យនៃអំពើលក់-ដូរមនុស្ស

មាត្រា ១៤ អំពើលក់-ដូរមនុស្ស

មាត្រា ១៥ អំពើលក់-ដូរមនុស្សដោយមានគោលដៅ

មាត្រា ១៦ អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន

មាត្រា ១៧ ការរឹតជាប់ដោយមានគោលដៅ

មាត្រា ១៨ អំពើនាំឆ្លងដែន

មាត្រា ១៩ ការទទួលយកមនុស្សដោយមានគោលដៅ

មាត្រា ២០ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស

ROYAUME du CAMBODGE MINISTRE du PALAIS ROYAL

ជំពូកទី ៣ ការបង្ខាំង

មាត្រា ២១ ការចាប់ពង្រត់ ការឃុំឃាំង ឬ ការបង្ខាំង

មាត្រា ២២ ស្ថានទម្ងន់ទោស

ជំពូកទី ៤ អំពើពេស្យាចារ និងអំពើពេស្យាចារកុមារ

មាត្រា ២៣ និយមន័យនៃអំពើពេស្យាចារ និងអំពើពេស្យាចារកុមារ

មាត្រា ២៤ អំពើអូសទាញ

មាត្រា ២៥ និយមន័យនៃសញ្ហារកម្ម

មាត្រា ២៦ សញ្ហារកម្ម

មាត្រា ២៧ ស្ថានទម្ងន់ទោសនៃសញ្ហារកម្ម

មាត្រា ២៨ សញ្ហារកម្មទាក់ទងនឹងពេស្យាចារកុមារ

មាត្រា ២៩ សញ្ហារកម្មដោយមានការធ្វើទារុណកម្ម

មាត្រា ៣០ ការជឹកនាំពេស្យាចារ

មាត្រា ៣១ ការជឹកនាំគ្រឹះស្ថានពេស្យាចារ

មាត្រា ៣២ ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ

មាត្រា ៣៣ បទល្មើសទាក់ទងនឹងពេស្យាចារកុមារ

មាត្រា ៣៤ ការទិញពេស្យាចារកុមារ

មាត្រា ៣៥ អំពើអូសទាញពេស្យាចារកុមារ

មាត្រា ៣៦ ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ

មាត្រា ៣៧ កិច្ចសន្យានៃអំពើពេស្យាចារកុមារ

ជំពូកទី ៥ រូបភាព និង សម្ភារៈអាសអាភាស

មាត្រា ៣៨ និយមន័យនៃរូបភាពនិងសម្ភារៈអាសអាភាស

មាត្រា ៣៩ រូបភាព និងសម្ភារៈអាសអាភាស

មាត្រា ៤០ និយមន័យនៃរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ

មាត្រា ៤១ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL •

ជំពូកទី ៦ អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ

មាត្រា ៤២ អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ

មាត្រា ៤៣ អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ

មាត្រា ៤៤ ការលើកលែងពីការផ្តន្ទាទោស

ជំពូកទី ៧ សំណងរដ្ឋប្បវេណី

មាត្រា ៤៥ កំប្លុសន្យាសម្រាប់អំពើលក់-ជួរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

មាត្រា ៤៦ សំណងបដិទានលើការទទួលបានផលប្រយោជន៍ដោយមិនសមហេតុផល

មាត្រា ៤៧ សិទ្ធិជាអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិដែលត្រូវគេរឹបអូស

ជំពូកទី ៨ បទប្បញ្ញត្តិបន្ថែម

មាត្រា ៤៨ ទោសបន្ថែម

មាត្រា ៤៩ ការលាក់បាំងនូវអត្តសញ្ញាណនៃជនរងគ្រោះ

ជំពូកទី ៩ អវសានប្បញ្ញត្តិ

មាត្រា ៥០ និរាករណ៍នៃច្បាប់ដែលផ្ទុយ

មាត្រា ៥១ ការជំនួសដោយក្រមព្រហ្មទណ្ឌ

មាត្រា ៥២ ការអនុវត្តច្បាប់នេះ

ន.ស/រកត/០៣០៨/ ២២៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាឥស្សរត្រ
ខេមរាជនា សម្ងហោតាស តម្ងជាឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ងជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស.រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជាតាមឋានានុក្រមដល់ សមាជិក សមាជិកា រដ្ឋសភា នីតិកាលទី៣ លើកទី២ចំនួន ១២៣ រូប និងអគ្គលេខាធិការ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ចំនួន ៤រូប ដូចមានរាយព្រះនាម និងនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស ឯករាជ្យជាតិ

១- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** តំណាងរាស្ត្រមណ្ឌលកំពង់ចាម ប្រធានរដ្ឋសភា

២- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកសាមញ្ញ

៣- សម្តេចចៅហ្វាវាំង **ងួន សំអុល** តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកសាមញ្ញ

៤- ឯកឧត្តម **ស ខេង** តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកសាមញ្ញ

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវង្សាឍ្យ

១-	ឯកឧត្តម **ប៉ែន បញ្ញោ**	តំណាងរាស្ត្រមណ្ឌលព្រៃវែង ប្រធានគណៈកម្មការនីតិកម្ម និង យុត្តិធម៌
២-	លោកជំទាវ **ហូ ណូន**	តំណាងរាស្ត្រមណ្ឌលកណ្តាលប្រធានគណៈកម្មការ សុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

ROYAUME du CAMBODGE

៣-	ឯកឧត្តម	សុន ឆ័យ	តំណាងរាស្ត្រមណ្ឌលភ្នំពេញ ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការ អន្តរជាតិ ឃោសនាការ និងព័ត៌មាន
៤-	លោកជំទាវ	និន សាផុន	តំណាងរាស្ត្រមណ្ឌលតាកែវ អនុប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
៥-	ឯកឧត្តម	ឆ្លុន និច	តំណាងរាស្ត្រមណ្ឌលកំពង់ធំ អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦-	ឯកឧត្តម	សោម ចិន	តំណាងរាស្ត្រមណ្ឌលកំពត លេខាធិការគណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
៧-	ឯកឧត្តម	ង៉ែត សីវុឡ	តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកសាមញ្ញ
៨-	ឯកឧត្តម	ចាន់ ង៉ែន	អគ្គលេខាធិការដ្ឋាន អគ្គលេខាធិការរងរដ្ឋសភា

ក- <u>គ្រឿងឥស្សរិយយស ម្ចាស់សារត៍ណ្ឌ ថ្នាក់ មហាសេរីតន្តន៍</u>

១-	ឯកឧត្តម	ឡូន ញ៊ិល	តំណាងរាស្ត្រមណ្ឌលកំពង់ធំ អនុប្រធានទី១ រដ្ឋសភា
២-	ឯកឧត្តម	ហ្វុង ស៊ុនហួត	តំណាងរាស្ត្រមណ្ឌលកណ្តាល អនុប្រធានទី២ រដ្ឋសភា
៣-	ឯកឧត្តម	ជាម យៀប	តំណាងរាស្ត្រមណ្ឌលព្រៃវែង ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម
៤-	ឯកឧត្តម	ម៉ូម ឌីមហ៊ុយ	តំណាងរាស្ត្រមណ្ឌលកណ្តាល ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការ សាសនា វប្បធម៌ និងទេសចរណ៍
៥-	ឯកឧត្តម	ម៉ៅ ញ្ញ សាផាន	តំណាងរាស្ត្រមណ្ឌលកំពង់ចាម អនុប្រធានគណៈកម្មការនីតិកម្ម និង យុត្តិធម៌
៦-	សម្តេច	នរោត្តម ឧជវ៉ា	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកាគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និង ព័ត៌មាន
៧-	ឯកឧត្តម	តាត ឈន់	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ
៨-	ឯកឧត្តម	ស្ងួ អាន	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកសាមញ្ញ
៩-	សម្តេច	នរោត្តម សីវុឡ	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកសាមញ្ញ

១០- លោកជំទាវ	ម៉ែន សំអន	តំណាងរាស្ត្រមណ្ឌលស្វាយរៀង	សមាជិកាសាមញ្ញ
១១- ឯកឧត្តម	ឡៅ ជាញ៉ុំ	តំណាងរាស្ត្រមណ្ឌលសៀមរាប	សមាជិកសាមញ្ញ
១២- ឯកឧត្តម	សាយ ឈុំ	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ	សមាជិកសាមញ្ញ
១៣- ឯកឧត្តម	ស៊ៀច ណាំ	តំណាងរាស្ត្រមណ្ឌលសៀមរាប	សមាជិកសាមញ្ញ
១៤- ឯកឧត្តម	ឯក សំអូល	តំណាងរាស្ត្រមណ្ឌលព្រៃវែង	អតីតសមាជិករដ្ឋសភា
១៥- ឯកឧត្តម	គីម សាន្ត	អគ្គលេខាធិការដ្ឋាន	អគ្គលេខាធិការរងរដ្ឋសភា

ឃ- គ្រឿងឥស្សរិយយស **ស្វ័ចភ្ការ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកជំទាវ	**គី សំអេង**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង ប្រធានគណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់	
២- ឯកឧត្តម	**ជា សុទ្ធ**	តំណាងរាស្ត្រមណ្ឌល ព្រៃវែង	សមាជិកសាមញ្ញ
៣- ឯកឧត្តម	**នៃ ប៉ែលរ**	តំណាងរាស្ត្រមណ្ឌល កំពត	សមាជិកសាមញ្ញ
៤- ឯកឧត្តម	**ចួ ថង**	តំណាងរាស្ត្រមណ្ឌល រតនគីរី	សមាជិកសាមញ្ញ

ង- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស្វីស្វភត្តិមុនីវឌ្ឍ ភ្នុសុមៈ នារីរត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម	**ញឹម ភណ្ឌដា**	តំណាងរាស្ត្រមណ្ឌលព្រៃវែង	សមាជិកសាមញ្ញ
២- ឯកឧត្តម	**ហោ ណាំហុង**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម	សមាជិកសាមញ្ញ

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១- លោកជំទាវ	**ឃួន សុដារី**	តំណាងរាស្ត្រមណ្ឌលកណ្តាល ប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា	
២- ឯកឧត្តម	**យឹម សុភណ្ឌ**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត ប្បោសសំអាត និងមុខងារសាធារណៈ	
៣- ឯកឧត្តម	**ថាន់ ស្ទឺណា**	តំណាងរាស្ត្រមណ្ឌលកំពត ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ ជនបទ បរិស្ថាន និងធនធានទឹក	
៤- ឯកឧត្តម	**ទ្រី ឈាងហ៊ួត**	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ អនុប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក	

៥-	ឯកឧត្តម	**សរិត ឫទ្ធ**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ លេខាធិការគណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
៦-	ឯកឧត្តម	**ហ៊ូ ស្រ៊ី**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាន
៧-	ឯកឧត្តម	**សោម ខន**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ សមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍
៨-	ឯកឧត្តម	**មីន សារ៉ន**	តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌
៩-	ឯកឧត្តម	**ជិន គីមស្រេង**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១០-	ឯកឧត្តម	**ស៊ុត សំអេង**	តំណាងរាស្ត្រមណ្ឌលព្រះវិហារ សមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
១១-	ឯកឧត្តម	**ម៉ុយ ចាត**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
១២-	លោកជំទាវ	**សោម គីមស៊ូគី**	តំណាងរាស្ត្រមណ្ឌល កំពត សមាជិកសាមញ្ញ
១៣-	ឯកឧត្តម	**ឃី តាំងលីម**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ

ន- <u>ត្រឿងឥស្សរិយយស **មុនីសារភ័ណ្ឌ ថ្នាក់ **មហាសេនា**</u>**

១-	ឯកឧត្តម	**អាយ ខន**	តំណាងរាស្ត្រមណ្ឌលកោះកុង លេខាធិការគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក
២-	ឯកឧត្តម	**ខៀវ សន**	តំណាងរាស្ត្រមណ្ឌលកណ្តាល លេខាធិការគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា
៣-	ឯកឧត្តម	**នាង ស៊ីថុង**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៤-	ឯកឧត្តម	**អ៊ឹង ប៊ុនហ៊ីង**	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៥-	ឯកឧត្តម	**ញ៉ែម ថ្ងាឌី**	តំណាងរាស្ត្រមណ្ឌលកំពង់ធំ សមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា
៦-	ឯកឧត្តម	**ស៊ឹម សូលី**	តំណាងរាស្ត្រមណ្ឌលកំពង់ធំ សមាជិកគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៧-	ឯកឧត្តម	**អេម៉ាត់ ប៉ះយ៉ា**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ
៨-	ឯកឧត្តម	**ខែត ប៉ារ៉ាឌី**	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកសាមញ្ញ
៩-	ឯកឧត្តម	**ឈាង ពាន់ប៉ាមីន**	តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកសាមញ្ញ

៤- <u>ត្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបតិន្ទ</u>

១-	ឯកឧត្តម	**សួរ ភិូចធ័រ**	តំណាងរាស្ត្រមណ្ឌលស្វាយរៀង អនុប្រធានគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
២-	ឯកឧត្តម	**ជាម ច័ន្ទនី**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម អនុប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា
៣-	ឯកឧត្តម	**ចៅ សុភណ្ឌ**	តំណាងរាស្ត្រមណ្ឌលកណ្តាល លេខាធិការគណៈកម្មការនីតិកម្ម និងយុត្តិធម៌
៤-	ឯកឧត្តម	**ចាន់ ចេង**	តំណាងរាស្ត្រមណ្ឌលកណ្តាល លេខាធិការគណៈកម្មការ សុខាភិបាល សង្គមកិច្ចអតីត យុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
៥-	ឯកឧត្តម	**ហួរ ប៉ាន់**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ លេខាធិការគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៦-	ឯកឧត្តម	**ខែត សំអូន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៧-	ឯកឧត្តម	**ភ្ញៀង ប៉ាង**	តំណាងរាស្ត្រមណ្ឌលកំពត សមាជិកគណៈកម្មការ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
៨-	ឯកឧត្តម	**សាយ មន្ថល**	តំណាងរាស្ត្រមណ្ឌលពោធិសាត់ សមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និង មុខងារសាធារណៈ

៩-	លោកជំទាវ ជួញ សុវណ្ណ	តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកាគណៈកម្មការ សុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
១០-	ឯកឧត្តម ប៉ែត សំឆាយ	តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកគណៈកម្មការនីតិកម្ម និង យុត្តិធម៌

យ- <u>ត្រឿងឥស្សរិយយស មុនីសារាតីណ្ឌ ថ្នាក់ ឱបថិន្ទ</u>

១-	ឯកឧត្តម ហ៊ាង សំអឿន	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ អនុប្រធានគណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត ឃោសសំអាត និងមុខងារសាធារណៈ
២-	ព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ សន្ធា	តំណាងរាស្ត្រមណ្ឌលព្រៃវែង អនុប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ចអតីត យុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
៣-	លោកជំទាវ អ៊ឹម រុន	តំណាងរាស្ត្រមណ្ឌលកំពង់ចាម លេខាធិការគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៤-	ឯកឧត្តម លី សុន	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ សមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌
៥-	ឯកឧត្តម អ៊ុំ ញ៉ាញ់	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦-	ឯកឧត្តម ចៅ សូដូន	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកគណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៧-	ឯកឧត្តម ហ្វង សុខហៀង	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
៨-	ឯកឧត្តម ហ៊ិល សាម៉ន្ត	តំណាងរាស្ត្រមណ្ឌលស្វាយរៀង សមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត ឃោសសំអាត និងមុខងារសាធារណៈ
៩-	ឯកឧត្តម អៀ លីមសួរ	តំណាងរាស្ត្រមណ្ឌលកំពត សមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
១០-	ឯកឧត្តម ជ្រាត់ ឆុច	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

១១-	ឯកឧត្តម	គីមសួរ តីរិទ្ធ	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ	សមាជិកគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
១២-	ឯកឧត្តម	ស្ងាន ឡៀត	តំណាងរាស្ត្រមណ្ឌលពោធិសាត់	សមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
១៣-	លោកជំទាវ	លី គីមលៀង	តំណាងរាស្ត្រមណ្ឌលបាត់ដំបង	សមាជិកាគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
១៤-	ឯកឧត្តម	ឃុស សុន	តំណាងរាស្ត្រមណ្ឌលកំពង់ចាម	សមាជិកគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
១៥-	ឯកឧត្តម	សួស គាណាន	តំណាងរាស្ត្រមណ្ឌលក្រុងព្រះសីហនុ	សមាជិកសាមញ្ញ
១៦-	ឯកឧត្តម	សម រង្ស៊ី	តំណាងរាស្ត្រមណ្ឌលកំពង់ចាម	សមាជិកសាមញ្ញ
១៧-	លោកជំទាវ	ជូឡូច សូម្ហរ៉ា	តំណាងរាស្ត្រមណ្ឌលភ្នំពេញ	សមាជិកាសាមញ្ញ
១៨-	លោកជំទាវ	ដួច ឥណ្ណា	តំណាងរាស្ត្រមណ្ឌលស្វាយរៀង	សមាជិកាសាមញ្ញ
១៩-	ឯកឧត្តម	នួន សុខ	តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង	សមាជិកសាមញ្ញ
២០-	ឯកឧត្តម	រ័ត្ន សារឹម	តំណាងរាស្ត្រមណ្ឌលមណ្ឌលគីរី	សមាជិកសាមញ្ញ
២១-	ឯកឧត្តម	ឥច គាន	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ	សមាជិកសាមញ្ញ
២២-	ឯកឧត្តម	ស្ងិត ប៊ុនហួត	តំណាងរាស្ត្រមណ្ឌលកំពង់ធំ	សមាជិកសាមញ្ញ
២៣-	ឯកឧត្តម	ឡេង ប៉េងឡេង	អគ្គលេខាធិការដ្ឋាន	អគ្គលេខាធិការរដ្ឋសភា

ញ- <u>ត្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា</u>

១-	លោកជំទាវ	ម៉ែន មុន្នីរតនា	តំណាងរាស្ត្រមណ្ឌលព្រៃវែង	សមាជិកាគណៈកម្មការវិជ្ជនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
២-	ឯកឧត្តម	នួ សុភក្តិ	តំណាងរាស្ត្រមណ្ឌលភ្នំពេញ	សមាជិកគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៣-	ឯកឧត្តម	ហែម សាមិន	តំណាងរាស្ត្រមណ្ឌលកណ្តាល	សមាជិកសាមញ្ញ
៤-	ឯកឧត្តម	សុខ សាឃុ	តំណាងរាស្ត្រមណ្ឌលព្រៃវែង	សមាជិកសាមញ្ញ
៥-	លោកជំទាវ	ម៉ាត់ សាលីម៉ា	តំណាងរាស្ត្រមណ្ឌលកំពង់ចាម	សមាជិកាសាមញ្ញ
៦-	ឯកឧត្តម	សួរ ណាត	តំណាងរាស្ត្រមណ្ឌលកំពង់ចាម	សមាជិកសាមញ្ញ
៧-	ឯកឧត្តម	ហ៊ិល ប៊ុនថា	អគ្គលេខាធិការដ្ឋាន	អគ្គលេខាធិការរងរដ្ឋសភា

៩- ត្រៀងឥស្សរិយយស អ្នឧីសារាតំណាង ថ្នាក់ សេនា

១-	ឯកឧត្តម	ឡឿ សុផល	តំណាងរាស្ត្រមណ្ឌលក្រចេះ សមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
២-	ឯកឧត្តម	ម៉ី ឈាន	តំណាងរាស្ត្រមណ្ឌលពោធិសាត់ សមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា
៣-	លោកជំទាវ	ចែម សាវ៉ៃ	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកាគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
